**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៣១...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## នីតិវិធីនៃការបង្កើត ការរំលាយចោល និងការកំណត់ តួនាទីនិងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីបង្កើតក្រសួងធនធានទឹកនិងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹកនិងឧតុនិយម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងធានាបាននូវការគ្រប់គ្រងនិងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីនីតិវិធីនៃការបង្កើត ការរំលាយចោល ហើយនិងតួនាទីនិងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សហគមន៍កសិករប្រើប្រាស់ទឹកសរសេរជាអក្សរកាត់ថា **ស.ក.ប.ទ.**។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ **ស.ក.ប.ទ.** ទាំងអស់ ដែលប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ ..**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់នៅក្នុងអនុក្រឹត្យនេះ រួមមាន៖

១. **ស.ក.ប.ធ.** សំដៅដល់ការចងក្រងប្រមូលផ្តុំកសិករប្រើប្រាស់ទឹក នៅក្នុងប្រព័ន្ធធារាសាស្ត្រមួយ ដើម្បីប្រើប្រាស់និងថែរក្សាឲ្យមាននិរន្តរភាព។

២. **ការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ** សំដៅដល់ការប្រគល់ការទទួលខុសត្រូវសមស្របដល់ **ស.ក.ប.ធ.** ក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រដោយមានការទទួលស្គាល់ជាផ្លូវការពីក្រសួងធនធានទឹកនិងឧតុនិយម។

៣. **ការស្រោចស្រព** សំដៅដល់ការផ្តល់និងការទទួលទឹកតាមរយៈប្រព័ន្ធធារាសាស្ត្រ សម្រាប់ផលិតកម្មកសិកម្ម។

៤. **ប្រព័ន្ធធារាសាស្ត្រ** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលពាក់ព័ន្ធនឹងការស្ទាក់ទឹក ការស្តុកទឹក ប្រព័ន្ធប្រឡាយចែកចាយទឹក និងដោះទឹក។ ប្រព័ន្ធប្រឡាយរួមមាន ប្រឡាយមេ ប្រឡាយរង និងប្រឡាយចែកចាយទឹក។

៥. **ការថែទាំប្រព័ន្ធធារាសាស្ត្រ** សំដៅដល់សកម្មភាពទាំងឡាយណាដែលធានាដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

៦. **ការជួសជុលនិងការស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រ** សំដៅដល់ការធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រមានទ្រង់ទ្រាយលក្ខណៈល្អប្រសើរនិងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។

៧. **ផែនការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ** សំដៅដល់ផែនការដែលលើកឡើងនូវរាល់សកម្មភាព និងតម្រូវការសម្រាប់ប្រើប្រាស់ ការថែទាំ ការកែលំអ ការជួសជុល និងការស្តារសម្រាប់រយៈពេលខ្លី មធ្យម និងវែង។

៨. **ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ** សំដៅដល់ការដឹកនាំ ការចាត់ចែងលើការប្រើប្រាស់ទឹក ការថែទាំ ការជួសជុល ការកែលំអហេដ្ឋារចនាសម្ព័ន្ធ ដោយមានការផ្តល់ហិរញ្ញប្បទាន ការអនុវត្តបទប្បញ្ញត្តិ និងការធ្វើនិយតកម្ម។

៩. **ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល និងកិច្ចអភិវឌ្ឍ** សំដៅដល់ការចូលរួមចំណែកពីអ្នកប្រើប្រាស់ទឹកតាមរយៈ **ស.ក.ប.ធ.** ក្នុងការផ្តល់យោបល់លើការស្តារ ការជួសជុលឬការសាងសង់ប្រព័ន្ធធារាសាស្ត្រថ្មីដោយរាជរដ្ឋាភិបាលឬដៃគូអភិវឌ្ឍ។

១០. **ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ** សំដៅដល់ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ និងការសាងសង់ថ្មី។

១១. **តំបន់ទទួលសេវាកម្មស្រោចស្រព** សំដៅដល់ផ្ទៃដីដាំដុះដែលទទួលទឹកស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ។

១២. **ផែនការសេវាកម្មស្រោចស្រព** សំដៅដល់ផែនការក្នុងការបែងចែកទឹកប្រចាំរដូវឬប្រចាំឆ្នាំ ដែលត្រូវបង្ហាញពីសេវាកម្មថែទាំ បរិមាណផ្ទៃដីស្រោចស្រព ការផ្តល់ទឹកស្រោចស្រព ការដាំដុះ ការធ្វើហិរញ្ញប្បទាន និងការកំណត់ភាគទានប្រើប្រាស់ទឹក។

១៣. **ភាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ** សំដៅដល់ការចូលរួមជាថវិកាឬសម្ភារៈរបស់អ្នកដែលបានទទួលផលប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រ ដើម្បីទ្រទ្រង់ប្រព័ន្ធធារាសាស្ត្រនោះ។

១៤. **ការធ្វើអធិការកិច្ច** សំដៅដល់ការត្រួតពិនិត្យ ការវាយតម្លៃ និងការសន្និដ្ឋានលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ការអនុវត្តការងាររបស់ **ស.ក.ប.ធ.** ក្នុងនោះរួមមានថវិកា ការងារបច្ចេកទេស ការងារដឹកនាំ និងការងារគ្រប់គ្រង។

១៥. **អ្នកប្រើប្រាស់ទឹក** សំដៅដល់កសិករឬបុគ្គលដែលបានប្រើប្រាស់ទឹកពីប្រព័ន្ធធារាសាស្ត្រ។

១៦. **សិទ្ធិប្រើប្រាស់ទឹកទ្រង់ទ្រាយតូចនិងមធ្យមក្នុងប្រព័ន្ធធារាសាស្ត្រ** សំដៅដល់ការផ្តល់លិខិតអនុញ្ញាតប្រើប្រាស់ទឹកជាផ្លូវការដោយ **ស.ក.ប.ធ.** ទៅដល់គ្រប់ស្ថាប័ន អង្គភាព ឬអ្នកប្រើប្រាស់ទឹក ដោយផ្អែកលើកិច្ចព្រមព្រៀងរវាងភាគីអ្នកផ្តល់និងអ្នកទទួល។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

ក្រសួងធនធានទឹកនិងឧតុនិយមមានសមត្ថកិច្ចទូទៅលើការគ្រប់គ្រង **ស.ក.ប.ធ.** ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ជាអាណាព្យាបាលលើ **ស.ក.ប.ធ.** និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រទាំងអស់
- ផ្តល់ការឯកភាពលើការស្នើសុំចុះបញ្ជី **ស.ក.ប.ធ.**
- បដិសេធឬរំលាយចោល **ស.ក.ប.ធ.**
- ចេញគោលការណ៍ណែនាំអំពីតំរូវលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ **ស.ក.ប.ធ.** និងចូលរួមផ្សព្វផ្សាយឲ្យបានទូលំទូលាយ
- សម្របសម្រួលជាមួយនឹងស្ថាប័នរដ្ឋនិងភាគីពាក់ព័ន្ធផ្សេងទៀត លើការអនុវត្តនិងការអភិវឌ្ឍក្នុងការគ្រប់គ្រង **ស.ក.ប.ធ.**
- សម្របសម្រួលនិងរៀបចំដំណើរការបោះឆ្នោតជ្រើសតាំងសមាសភាពនៃគណៈកម្មាធិការ **ស.ក.ប.ធ.**
- ធ្វើអន្តរាគមន៍ក្នុងការដោះស្រាយទំនាស់របស់ **ស.ក.ប.ធ.**
- ជួយស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានដើម្បីឧបត្ថម្ភនិងគាំទ្រ **ស.ក.ប.ធ.**
- បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាព **ស.ក.ប.ធ.**។

**មាត្រា៦ .-**

មន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្តទទួលខុសត្រូវលើការចុះបញ្ជី **ស.ក.ប.ធ.** បន្ទាប់ពីមានការឯកភាពពីក្រសួងធនធានទឹកនិងឧតុនិយម។

## ជំពូកទី៣
## ការបង្កើតនិងការរំលាយចោល ស.ក.ប.ធ.

**មាត្រា៧ .-**

**ស.ក.ប.ធ.** ជារូបវន្តបុគ្គលមួយក្រុមដែលបម្រើផលប្រយោជន៍រួមឲ្យប្រជាពលរដ្ឋ តាមរយៈការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព ដើម្បីរួមចំណែកលើកតម្កើងសេដ្ឋកិច្ចសង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ។

**ស.ក.ប.ធ.** ត្រូវបង្កើតឡើងដោយផ្អែកលើ៖

- កសិករដែលប្រើប្រាស់ទឹកជាមួយគ្នាក្នុងប្រព័ន្ធធារាសាស្ត្រ ឬផ្នែកណាមួយនៃប្រព័ន្ធនេះ
- បទដ្ឋានបច្ចេកទេសរបស់ក្រសួងធនធានទឹកនិងឧតុនិយម
- ការចូលរួមបោះឆ្នោតពីប្រជាពលរដ្ឋដែលប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រស្ថិតក្នុងដែនអំណាចរបស់ **ស.ក.ប.ធ.** និងដោយមានសំឡេងឆ្នោតគាំទ្រចំនួន២/៣(ពីរភាគបី)។ ប្រជាជននិងកសិករទាំងអស់ដែលប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រស្ថិតក្នុងដែនអំណាចរបស់ **ស.ក.ប.ធ.** អាចដាក់ពាក្យសុំចូលជាសមាជិក ទោះបីមិនបានចូលរួមបោះឆ្នោតក៏ដោយ
- ច្បាប់ បទបញ្ជា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**មាត្រា៨ .-**

ការរំលាយចោល **ស.ក.ប.ធ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

## ជំពូកទី៤
## សមាជិកភាព តួនាទី ភារកិច្ច និងសិទ្ធិរបស់ ស.ក.ប.ធ.

**មាត្រា៩ .-**

ប្រជាពលរដ្ឋដែលមានបំណងចូលជាសមាជិក **ស.ក.ប.ធ.** ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ជាម្ចាស់ដីឬអ្នកជួលដីពីគេដែលមានផ្ទៃដីស្ថិតក្នុងប្រព័ន្ធធារាសាស្ត្រនោះ
- មានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ ចំពោះម្ចាស់ដីឬអ្នកជួលដីពីគេជាអនីតិជន ត្រូវមានតំណាងស្រប ច្បាប់ វៀរលែងតែអនីតិជនដែលទទួលអត្តាធីនភាព
- ត្រូវដាក់ពាក្យសុំចូលជាសមាជិក **ស.ក.ប.ធ.** ដោយមានស្នាមមេដៃ។

**មាត្រា១០ .-**

សមាជិកភាពនៃ **ស.ក.ប.ធ.** ត្រូវបាត់បង់ក្នុងករណីដូចខាងក្រោម៖

- ទទួលមរណភាព
- ជួល លក់ ឬផ្ទេរដីរបស់ខ្លួនទាំងស្រុងឲ្យអ្នកដទៃ
- ឈប់ជួលដីពីគេ
- មិនគោរពតាមច្បាប់ បទបញ្ញា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងរបស់ **ស.ក.ប.ធ.** ហើយត្រូវបានបញ្ចប់សមាជិកភាពដោយគណៈកម្មាធិការ **ស.ក.ប.ធ.**។

**មាត្រា១១ .-**

**ស.ក.ប.ធ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ចូលរួមគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យធារាសាស្ត្រ
- គោរពតាមការណែនាំរបស់ក្រសួងធនធានទឹកនិងឧតុនិយម
- អនុវត្តច្បាប់ បទបញ្ញា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ លក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងរបស់ **ស.ក.ប.ធ.**
- រៀបចំផែនការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដើម្បីធានាការអនុវត្តលើការងារជួសជុល ការកែលំអ និងការបង្កើនលទ្ធភាពរបស់ប្រព័ន្ធធារាសាស្ត្រ
- ចូលរួមធ្វើអធិការកិច្ចលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រតាមការកំណត់ និងអនុលោមតាមនិយតកម្ម ច្បាប់ បទបញ្ញា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ផ្តល់ព័ត៌មាន ពិគ្រោះយោបល់ និងស្នើសុំការគាំទ្រពីរដ្ឋបាលថ្នាក់ក្រោមជាតិអំពីផែនការសកម្មភាព និងការធ្វើសេចក្តីសម្រេចណាមួយដែលមានសារៈសំខាន់ចំពោះការងារអភិវឌ្ឍមូលដ្ឋាន
- ការពារផ្ទៃដីក្នុងអាងទឹក និងបរិវេណជុំវិញប្រព័ន្ធធារាសាស្ត្រ ដើម្បីទប់ស្កាត់ការបំពានពីគ្រប់មជ្ឈដ្ឋាន
- ជំរុញឲ្យសមាជិកបង់ភាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ
- ដោះស្រាយវិវាទដែលកើតឡើងពីការប្រើប្រាស់ទឹកនិងការចែកចាយទឹក ក្នុងគោលបំណងផ្សេងៗគ្នា
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំជូនទៅក្រសួងធនធានទឹកនិងឧតុនិយម។

**មាត្រា១២ .-**

**ស.ក.ប.ធ.** មានសិទ្ធិដូចខាងក្រោម៖

- អនុម័តឬកែប្រែលក្ខន្តិកៈនិងបទបញ្ញាផ្ទៃក្នុងរបស់ **ស.ក.ប.ធ.**
- ជ្រើសតាំង និងផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការ **ស.ក.ប.ធ.** ទៅតាមលក្ខន្តិកៈ **ស.ក.ប.ធ.**/...

- ទទួលផលពីធនធានធម្មជាតិក្នុងដែនប្រព័ន្ធធារាសាស្ត្រទាំងមូល រួមទាំងការធ្វើអាជីវកម្មផ្សេងៗ
- ប្រើប្រាស់ ចែកចាយ គ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រ
- បើកគណនីធនាគារ និងប្រើប្រាស់ថវិកាដោយផ្អែកលើលក្ខន្តិកៈ **ស.ក.ប.ធ.**
- ចុះកិច្ចសន្យាលើការផ្តល់ ការទទួលសេវាកម្មផ្សេងៗ ការជ្រើសរើស និងការផ្លាស់ប្តូរអ្នកផ្តល់សេវាកម្មជាមួយភាគីផ្សេងៗទៀតដែលមានផលប្រយោជន៍ដល់ **ស.ក.ប.ធ.**
- ស្នើសុំជំនួយហិរញ្ញវត្ថុ បច្ចេកទេស ឬជំនួយឯទៀតពីរាជរដ្ឋាភិបាលឬភាគីដទៃទៀត
- ស្នើសុំ និងជ្រើសរើសសេវាកម្មគាំទ្រពីស្ថាប័នផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល អង្គការអភិវឌ្ឍន៍វិស័យឯកជន និងសប្បុរសជននានា សម្រាប់ការកសាងសមត្ថភាពតាមតម្រូវការរបស់ **ស.ក.ប.ធ.**។

**មាត្រា១៣ ..**

**ស.ក.ប.ធ.** ពុំមានសិទ្ធិដូចខាងក្រោម៖

- លក់និងបែងចែកធ្វើជាកម្មសិទ្ធិឯកជននូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ទោះតាមរូបភាពណាក៏ដោយ
- ចុះកិច្ចព្រមព្រៀងផ្សេងៗជាមួយរូបវន្តបុគ្គលឬនីតិបុគ្គលនានា ក្នុងការកែប្រែឬការសាងសង់ថ្មីនូវទីតាំងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រដោយពុំមានការអនុញ្ញាតពីក្រសួងធនធានទឹកនិងឧតុនិយម។

**មាត្រា១៤ ..**

សមាជិករបស់ **ស.ក.ប.ធ.** មានកាតព្វកិច្ចដូចខាងក្រោម៖

- គោរពនិងអនុវត្តច្បាប់ បទបញ្ញា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្ររបស់ **ស.ក.ប.ធ.**
- ចូលរួមការពារមច្ឆជាតិ សត្វព្រៃ និងព្រៃនៅក្នុងអាងទឹក បរិវេណជុំវិញ ឬក្នុងប្រព័ន្ធធារាសាស្ត្រ
- ជួយគណៈកម្មាធិការក្នុងការការពារប្រព័ន្ធធារាសាស្ត្រ ឲ្យមានដំណើរការប្រកបដោយនិរន្តរភាព
- ប្រើប្រាស់ទឹកទៅតាមបរិមាណដែលកំណត់ដោយគណៈកម្មាធិការ **ស.ក.ប.ធ.**
- ពិនិត្យមើលការបែងចែកទឹកជាប្រចាំនៅពេលបង្ហូរចូលតំបន់ដាំដុះឬកសិដ្ឋានរបស់ខ្លួនដើម្បីកាត់បន្ថយការប្រើប្រាស់ដោយខ្ជះខ្ជាយ
- បង់ភាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ និងចូលរួមជាពលកម្មឬជាសម្ភារៈដែលតម្រូវដោយ **ស.ក.ប.ធ.** ដើម្បីធានាបាននូវកិច្ចដំណើរការនិងការថែទាំប្រព័ន្ធធារាសាស្ត្រឲ្យមាននិរន្តរភាពនិងការអភិវឌ្ឍផ្សេងៗរបស់ **ស.ក.ប.ធ.**
- ផ្តល់ព័ត៌មានអំពីការបំផ្លិចបំផ្លាញឬការរំលោភបំពានដែលធ្វើឲ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រពីគ្រប់មូលដ្ឋានទៅដល់គណៈកម្មាធិការ **ស.ក.ប.ធ.** និងរដ្ឋបាលថ្នាក់ក្រោមជាតិនិងទប់ស្កាត់បទល្មើសទាំងនោះ។

**មាត្រា១៥ ..**

សមាជិករបស់ **ស.ក.ប.ធ.** មានសិទ្ធិដូចខាងក្រោម៖

- ចូលរួមបោះឆ្នោតអនុម័តឬកែប្រែលក្ខន្តិកៈ និង/ឬបទបញ្ជាផ្ទៃក្នុងរបស់ **ស.ក.ប.ធ.**
- បញ្ចេញយោបល់ក្នុងពេលប្រជុំដើម្បីកែលំអសកម្មភាពការងារ
- បោះឆ្នោតជ្រើសតាំងនិងផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការ **ស.ក.ប.ធ.**
- ឈរឈ្មោះបោះឆ្នោតក្នុងរចនាសម្ព័ន្ធគណៈកម្មាធិការ **ស.ក.ប.ធ.**
- បោះឆ្នោតគាំទ្រឬបដិសេធផែនការសកម្មភាពការងាររបស់ **ស.ក.ប.ធ.**/

- ទទួលបានការចែកចាយប្រើប្រាស់ទឹកសម្រាប់ការងារដាំដុះឬសេវាកម្មផ្សេងៗទៀតស្របតាមផែនការសេវាកម្មស្រោចស្រព
- ទទួលបានការដោះស្រាយវិវាទដោយយុត្តិធម៌និងសមធម៌
- ស្នើឲ្យបំភ្លឺរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗទៀតរបស់ **ស.ក.ប.ទ.** ក្នុងករណីមានការមន្ទិលសង្ស័យ
- លាលែងពីសមាជិកភាព។

## ជំពូកទី៥
## គណៈកម្មាធិការ ស.ក.ប.ទ.

**មាត្រា១៦ .-**

**ស.ក.ប.ទ.** ត្រូវដឹកនាំដោយគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកដែលហៅកាត់ថា គណៈកម្មាធិការ **ស.ក.ប.ទ.** ដែលត្រូវជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតរបស់សមាជិក **ស.ក.ប.ទ.**។ **ស.ក.ប.ទ.** ត្រូវចែកជាក្រុមកសិករប្រើប្រាស់ទឹកដែលសរសេរជាអក្សរកាត់ថា **ក.ក.ប.ទ.**។

ក្នុងករណីប្រព័ន្ធធារាសាស្ត្រណាមួយមានទ្រង់ទ្រាយធំនិងមានភាពស្មុគស្មាញច្រើន **ស.ក.ប.ទ.** អាចបង្កើតជាអនុក្រុមកសិករប្រើប្រាស់ទឹកដែលសរសេរជាអក្សរកាត់ថា **អ.ក.ក.ប.ទ.**។

គណៈកម្មាធិការ **ស.ក.ប.ទ.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - ប្រធាន | ១រូប | ទទួលបន្ទុករួម |
| - អនុប្រធានទី១ | ១រូប | ទទួលបន្ទុកលើផែនការថែទាំនិងជួសជុល |
| - អនុប្រធានទី២ | ១រូប | ទទួលបន្ទុកបែងចែកទឹក |
| - ហេរញ្ញិក | ១រូប | ទទួលបន្ទុកគ្រប់គ្រងថវិកា |

- ប្រធានក្រុមកសិករប្រើប្រាស់ទឹកទាំងអស់ជាសមាជិក។

ចំពោះប្រព័ន្ធធារាសាស្ត្រខ្នាតធំ ប្រធានគណៈកម្មាធិការ **ស.ក.ប.ទ.** មានសិទ្ធិស្នើទៅក្រសួងធនធានទឹកនិងឧតុនិយម ដើម្បីបង្កើតឲ្យមានសហប្រធានដែលជារដ្ឋបាលថ្នាក់ក្រោមជាតិតាមតម្រូវការជាក់ស្តែង។ សហប្រធានទាំងពីរត្រូវសម្រេចតាមគោលការណ៍សហព័ទ្ធសម្រេច។

ក្រុមនិងអនុក្រុមកសិករប្រើប្រាស់ទឹកមានសមាសភាពដូចខាងក្រោម៖

- ប្រធាន១រូប
- ជំនួយការមួយចំនួនតាមការចាំបាច់របស់ក្រុមនិងអនុក្រុម។

ប្រធានក្រុមឬអនុប្រធានក្រុមកសិករប្រើប្រាស់ទឹក ត្រូវបោះឆ្នោតជ្រើសតាំងដោយសមាជិកក្រុមឬអនុក្រុម។

**ស.ក.ប.ទ.** ត្រូវអញ្ជើញតំណាងសហគមន៍កសិកម្មដែលពាក់ព័ន្ធឲ្យចូលរួមផ្តល់យោបល់នៅក្នុងកិច្ចប្រជុំរបស់ខ្លួន ក្នុងករណីដែលមូលដ្ឋាននោះមានសហគមន៍កសិកម្ម។ ក្នុងករណីនេះ **ស.ក.ប.ទ.** ត្រូវចាត់តំណាងរបស់ខ្លួនឲ្យចូលរួមផ្តល់យោបល់នៅក្នុងកិច្ចប្រជុំរបស់សហគមន៍កសិកម្មតាមការអញ្ជើញ។

**មាត្រា១៧ .-**

អាណត្តិរបស់គណៈកម្មាធិការ **ស.ក.ប.ទ.** មានរយៈពេល៥ឆ្នាំ ហើយអាចបន្តរហូតដល់គណៈកម្មាធិការ **ស.ក.ប.ទ.** ថ្មីចូលមកជំនួស។

ក្នុងករណីដែលសមាសភាពគណៈកម្មាធិការ **ស.ក.ប.ទ.** ណាមួយទទួលមរណភាពឬលាលែងឬត្រូវបណ្តេញចេញមុនផុតអាណត្តិរយៈពេល៣ខែយ៉ាងតិច ត្រូវរៀបចំការបោះឆ្នោតបំពេញបន្ថែម។

អតីតសមាសភាពរបស់គណៈកម្មាធិការ **ស.ក.ប.ទ.** ដែលផុតអាណត្តិ មានសិទ្ធិឈរឈ្មោះសម្រាប់អាណត្តិថ្មីបាន។

ក្នុងករណីដែលប្រធាន **គ.គ.ប.ធ.** ឬ **អ.គ.គ.ប.ធ.** ណាមួយត្រូវបានជ្រើសតាំងជាប្រធាន អនុប្រធានឬហេរញ្ញិករបស់គណៈកម្មាធិការ **ស.គ.ប.ធ.** ក្រុមឬអនុក្រុមនោះត្រូវជ្រើសតាំងប្រធានមួយរូបទៀតជំនួស។

**មាត្រា១៨ ..**

នីតិវិធីនៃការជ្រើសតាំងគណៈកម្មាធិការ **ស.គ.ប.ធ.** ត្រូវបានធ្វើឡើងក្នុងពេលតែមួយតាមរយៈការបោះឆ្នោតដាច់ដោយឡែកពីគ្នាចំនួន៤លើក។ ការបោះឆ្នោតលើកទី១សម្រាប់ប្រធាន ការបោះឆ្នោតលើកទី២សម្រាប់អនុប្រធានទី១ ការបោះឆ្នោតលើកទី៣សម្រាប់អនុប្រធានទី២ និងការបោះឆ្នោតលើកទី៤សម្រាប់ហេរញ្ញិក។

ការបោះឆ្នោតអាចប្រព្រឹត្តទៅបានដោយមានវត្តមានរបស់សមាជិក **ស.គ.ប.ធ.** ចំនួន២/៣(ពីរភាគបី) នៃសមាជិកសរុប។

ការបោះឆ្នោតជ្រើសតាំងសមាសភាពគណៈកម្មាធិការ **ស.គ.ប.ធ.** ត្រូវធ្វើឡើងដោយសំឡេងភាគច្រើនដោយធៀប។ ក្នុងករណីមានសំឡេងស្មើគ្នា បេក្ខជនដែលមានវ័យចាស់ជាងគេត្រូវបានជ្រើសតាំង។

លទ្ធផលនៃការបោះឆ្នោតត្រូវបានទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

បែបបទនិងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការ **ស.គ.ប.ធ.** ប្រធាន **គ.គ.ប.ធ.** និងប្រធាន **អ.គ.គ.ប.ធ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

**មាត្រា១៩ ..**

គណៈកម្មាធិការ **ស.គ.ប.ធ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំកម្មវិធីការងាររបស់ **ស.គ.ប.ធ.**
- រៀបចំកសាងលក្ខន្តិកៈ កិច្ចសន្យា បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងស្តីពីការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងផែនការសេវាកម្មស្រោចស្រពរបស់ **ស.គ.ប.ធ**
- ថែរក្សាប្រព័ន្ធធារាសាស្ត្រឲ្យស្ថិតក្នុងលក្ខណៈល្អ ដើម្បីបម្រើកិច្ចដំណើរការស្រោចស្រពបានគ្រប់ពេលវេលា
- គ្រប់គ្រងនិងបែងចែកទឹកដល់សមាជិកសហគមន៍ឲ្យមានសុក្រឹតភាព
- ពង្រីកសមត្ថភាពនៃការប្រើប្រាស់ ការថែទាំ និងការអភិវឌ្ឍឲ្យកាន់តែល្អប្រសើរថែមទៀតនូវប្រព័ន្ធធារាសាស្ត្រ
- ផ្តល់របាយការណ៍អំពីកិច្ចការរបស់ **ស.គ.ប.ធ.** ទៅក្រសួងធនធានទឹកនិងឧតុនិយម ដើម្បីធ្វើការត្រួតពិនិត្យនិងវាយតម្លៃ
- ដោះស្រាយទំនាស់ដែលកើតមានឡើងក្នុងសហគមន៍លើការប្រើប្រាស់ទឹក
- ប្រមូលចំណូលពីភាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ និងធនធានក្នុងដែនប្រព័ន្ធធារាសាស្ត្ររួមទាំងការប្រមូលចំណូលពីការធ្វើអាជីវកម្មផ្សេងៗ នៅក្នុងប្រព័ន្ធធារាសាស្ត្ររបស់ **ស.គ.ប.ធ.** ដើម្បីយកទៅប្រើប្រាស់ក្នុងគោលដៅធានាកិច្ចដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រឲ្យមាននិរន្តរភាព
- ដាក់ពិន័យរដ្ឋបាលដល់សមាជិក **ស.គ.ប.ធ.** សមាជិកគណៈកម្មាធិការ **ស.គ.ប.ធ.** ប្រធាន **គ.គ.ប.ធ.** និងប្រធាន **អ.គ.គ.ប.ធ.** យោងទៅតាមលក្ខន្តិកៈ។

**មាត្រា២០ ..**

ប្រធានគណៈកម្មាធិការ **ស.គ.ប.ធ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ចាត់ចែងអញ្ជើញសមាជិក **ស.ក.ប.ឧ.** ចូលរួមប្រជុំ
- ដឹកនាំអង្គប្រជុំផ្សេងៗដែលពាក់ព័ន្ធនឹងការងារស្រោចស្រព
- ដឹកនាំរៀបចំផែនការស្រោចស្រពនៃឆ្នាំនីមួយៗ និងគម្រោងផែនការចំណាយ
- អនុវត្តការងារតាមគម្រោងផែនការនិងកម្មវិធីដែលមានការយល់ព្រមពីកិច្ចប្រជុំរបស់គណៈកម្មាធិការ **ស.ក.ប.ឧ.**
- ត្រួតពិនិត្យរាល់សកម្មភាពការងាររបស់ **ក.ក.ប.ឧ.**
- សហការការងារលើទំនាក់ទំនងសាធារណៈ
- អនុវត្តការចំណាយតាមការសម្រេចរបស់គណៈកម្មាធិការ **ស.ក.ប.ឧ.**
- ដាក់បញ្ចូលគម្រោងថវិកាប្រចាំឆ្នាំនិងកម្មវិធីការងាររបស់សហគមន៍ទៅក្នុងកិច្ចប្រជុំរបស់គណៈ-កម្មាធិការ **ស.ក.ប.ឧ.**
- ចុះហត្ថលេខាលើលិខិតយុត្តិការចំណូល ចំណាយរបស់ **ស.ក.ប.ឧ.**
- ធ្វើការផ្សះផ្សានិងសម្រេចលើទំនាស់ដែលកើតមានឡើងរវាងសមាជិកសហគមន៍។

ក្នុងករណីប្រធានអវត្តមាន ប្រធានត្រូវប្រគល់សិទ្ធិឲ្យអនុប្រធានទី១ឬអនុប្រធានទី២ដឹកនាំការងារជំនួស។ ក្នុងករណីដែលអនុប្រធានទាំងពីរអវត្តមាន ប្រធានត្រូវប្រគល់សិទ្ធិឲ្យសមាជិកណាម្នាក់ដឹកនាំការងារជំនួស។

**មាត្រា២១ .-**

អនុប្រធានទី១មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យជាប្រចាំនូវប្រព័ន្ធធារាសាស្ត្រ
- កំណត់ទំហំការងារដល់សមាជិក **ស.ក.ប.ឧ.** ដើម្បីអនុវត្តការងារជួសជុលនិងថែទាំ
- ទប់ស្កាត់គ្រប់សកម្មភាពបំផ្លាញប្រព័ន្ធធារាសាស្ត្រ
- លើកគម្រោងជួសជុលប្រព័ន្ធធារាសាស្ត្រ ដើម្បីដាក់ជូនគណៈកម្មាធិការ **ស.ក.ប.ឧ.** ដើម្បីពិនិត្យនិងសម្រេច
- រាយការណ៍ជាប្រចាំអំពីការងារជួសជុលប្រព័ន្ធធារាសាស្ត្រជូនគណៈកម្មាធិការ **ស.ក.ប.ឧ.**
- ជួយការងារប្រធានគណៈកម្មាធិការ **ស.ក.ប.ឧ.**។

**មាត្រា២២ .-**

អនុប្រធានទី២មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំកម្មវិធីស្រោចស្រពសម្រាប់ការដាំដុះដោយមានការឯកភាពគ្នាពីគ្រប់សមាជិក
- ប្រគល់ភារកិច្ចទទួលខុសត្រូវអនុវត្តកម្មវិធីស្រោចស្រពដល់ប្រធានក្រុមកសិករប្រើប្រាស់ទឹក
- ត្រួតពិនិត្យការអនុវត្តកម្មវិធីស្រោចស្រព និងរាយការណ៍ជូនប្រធានគណៈកម្មាធិការ **ស.ក.ប.ឧ.** អំពីសកម្មភាពការងារស្រោចស្រព
- ជួយការងារប្រធានគណៈកម្មាធិការ **ស.ក.ប.ឧ.**។

**មាត្រា២៣ .-**

ហេរញ្ញិកមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ប្រមូលកាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រពីសមាជិក តាមរយៈប្រធានក្រុមកសិករប្រើប្រាស់ទឹក
- កាន់បញ្ជិកាចំណូល ចំណាយនិងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ **ស.ក.ប.ឧ**
- គ្រប់គ្រងរាល់ចំណូលនិងចំណាយ និងជាបេឡាកររបស់ **ស.ក.ប.ឧ.**

- ធ្វើរបាយការណ៍អំពីស្ថានភាពចំណូលនិងចំណាយរបស់ **ស.ក.ប.ឆ.** ជូនគណៈកម្មាធិការ **ស.ក.ប.ឆ.**
- ចុះហត្ថលេខាលើរាល់ឯកសារចំណូល ចំណាយរបស់ **ស.ក.ប.ឆ.**។

**មាត្រា២៤ .-**

ប្រធានក្រុមកសិករប្រើប្រាស់ទឹកមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- អនុវត្តតាមកម្មវិធីការងាររបស់ **ស.ក.ប.ឆ.**
- សម្របសម្រួលការងាររវាងសមាជិកក្រុមនិងគណៈកម្មាធិការ **ស.ក.ប.ឆ.**
- ប្រមូលភាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រពីសមាជិកក្រុមរបស់ខ្លួន តាមការកំណត់របស់លក្ខន្តិកៈ **ស.ក.ប.ឆ.**។

ចំពោះប្រធានអនុក្រុមកសិករប្រើប្រាស់ទឹក មានតួនាទីនិងភារកិច្ចដូចគ្នានឹងប្រធានក្រុមកសិករប្រើប្រាស់ទឹកដែរ។

## ជំពូកទី៦
## នីតិវិធីនៃការចុះបញ្ជី ស.ក.ប.ឆ.

**មាត្រា២៥ .-**

គំរូលក្ខន្តិកៈ **ស.ក.ប.ឆ.** ត្រូវចែងអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- នាមករណ៍របស់ **ស.ក.ប.ឆ.**
- គោលបំណងនៃ **ស.ក.ប.ឆ.**
- លក្ខណសម្បត្តិចូលជាសមាជិក **ស.ក.ប.ឆ.**
- រចនាសម្ព័ន្ធរបស់ **ស.ក.ប.ឆ.**
- ឈ្មោះនិងអាសយដ្ឋានរបស់សមាជិកនៃគណៈកម្មាធិការ **ស.ក.ប.ឆ.** ដែលមានផ្ទៃដីស្ថិតក្នុងតំបន់ស្រោចស្រព
- អាណត្តិនិងការប្រព្រឹត្តទៅរបស់ **ស.ក.ប.ឆ.**
- ចំណូល ចំណាយ និងការត្រួតពិនិត្យរបស់ **ស.ក.ប.ឆ.**។

**មាត្រា២៦ .-**

លក្ខន្តិកៈ **ស.ក.ប.ឆ.** ត្រូវបានអនុម័តយល់ព្រមដោយសមាជិក។ គណៈកម្មាធិការ **ស.ក.ប.ឆ.** ត្រូវរៀបចំបែបបទដាក់ពាក្យសុំចុះបញ្ជី **ស.ក.ប.ឆ.** នៅមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្តដែល **ស.ក.ប.ឆ.** ស្ថិតនៅ។

**មាត្រា២៧ .-**

មន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្តមុននឹងចុះបញ្ជី **ស.ក.ប.ឆ.** ត្រូវរៀបចំនិងបញ្ជូនរាល់ឯកសារពាក់ព័ន្ធទាំងអស់ក្នុងរយៈពេលយ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានពាក្យសុំចុះបញ្ជីទៅក្រសួងធនធានទឹកនិងឧតុនិយមដើម្បីសុំការឯកភាព។

**មាត្រា២៨ .-**

ក្រសួងធនធានទឹកនិងឧតុនិយមត្រូវពិនិត្យនិងសម្រេចលើសំណើរបស់មន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្តក្នុងរយៈពេលមិនឲ្យលើសពី២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំ។

ក្នុងករណីដែលក្រសួងធនធានទឹកនិងឧតុនិយម ពិនិត្យឃើញថាពាក្យស្នើសុំពុំមានលក្ខណៈគ្រប់គ្រាន់ទេ មន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្តត្រូវបំពេញបន្ថែមលើពាក្យស្នើសុំចុះបញ្ជីនេះតាមការណែនាំរបស់ក្រសួងធនធានទឹកនិងឧតុនិយម។

ក្នុងករណីដែលមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត មិនអាចបំពេញបន្ថែមលើពាក្យស្នើសុំ

ចុះបញ្ជី **ស.ក.ប.ឆ.** តាមការណែនាំរបស់ក្រសួងធនធានទឹកនិងឧតុនិយមទេនោះ ក្រសួងធនធានទឹកនិងឧតុនិយមមានសិទ្ធិបដិសេធពាក្យស្នើសុំចុះបញ្ជីនេះ។

ក្នុងករណីដែលក្រសួងធនធានទឹកនិងឧតុនិយម មិនធ្វើការឆ្លើយតបនឹងសំណើសុំចុះបញ្ជី **ស.ក.ប.ឆ.** របស់មន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្តក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើទេនោះ ការចុះបញ្ជីត្រូវធ្វើឡើងដោយស្វ័យប្រវត្តិនៅមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត។

**មាត្រា២៩ .-**

បន្ទាប់ពីទទួលបានការឯកភាពពីក្រសួងធនធានទឹកនិងឧតុនិយម មន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្តត្រូវចាត់ចែងចុះបញ្ជី **ស.ក.ប.ឆ.** និងទទួលស្គាល់ជាផ្លូវការដើម្បីឲ្យ **ស.ក.ប.ឆ.** មានសិទ្ធិអនុវត្តលក្ខន្តិកៈរបស់ខ្លួន។

**មាត្រា៣០ .-**

**ស.ក.ប.ឆ.** ណាដែលបានចុះបញ្ជី **ស.ក.ប.ឆ.** រួចហើយ ហើយមានបំណងធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួន ត្រូវសុំការចុះបញ្ជីលក្ខន្តិកៈដែលធ្វើការកែប្រែនោះសាជាថ្មី ដោយរក្សាលំដាប់លេខរៀងបញ្ជី **ស.ក.ប.ឆ.** ចាស់ដដែល។

## ជំពូកទី៧

## ប្រភពធនធាន

**មាត្រា៣១ .-**

**ស.ក.ប.ឆ.** មានប្រភពធនធានមកពី៖

- ភាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលប្រមូលពីសមាជិក **ស.ក.ប.ឆ**
- ការយកវិភាគទានផ្សេងៗពីអ្នកធ្វើអាជីវកម្ម សេវាកម្ម នៅក្នុងអាងទឹកឬក្នុងប្រព័ន្ធធារាសាស្ត្រ
- ការរួមចំណែករបស់សមាជិក **ស.ក.ប.ឆ.** ជាកម្លាំងពលកម្ម និងការបង់ភាគទានដទៃទៀតដែលកំណត់ដោយ **ស.ក.ប.ឆ.**
- ហិរញ្ញប្បទានឬអំណោយពីដៃគូអភិវឌ្ឍនិងសប្បុរសជន
- ផលចំណេញដែលបានមកពីការធ្វើអាជីវកម្មរបស់ **ស.ក.ប.ឆ.**
- ប្រាក់ពិន័យរដ្ឋបាលផ្សេងៗ
- កញ្ចប់ថវិកាជាតិ
- ចំណូលផ្សេងៗទៀត។

**មាត្រា៣២ .-**

ការប្រើប្រាស់ធនធានរបស់ **ស.ក.ប.ឆ.** មានដូចតទៅ៖

- ប្រតិបត្តិការនិងការថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំ
- ការជួសជុល ការស្តារទ្រង់ទ្រាយតូច និងការកែលំអប្រព័ន្ធធារាសាស្ត្រជាប្រចាំ
- ការចូលរួមក្នុងការជួសជុល ការស្តារទ្រង់ទ្រាយធំ និងការបង្កើនលទ្ធភាពប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដោយថវិកាជាតិ ដៃគូអភិវឌ្ឍ ឬសប្បុរសជននានា
- ប្រាក់ឧបត្ថម្ភដល់គណៈកម្មាធិការ **ស.ក.ប.ឆ.** ការងាររដ្ឋបាល និងសម្ភារៈប្រើប្រាស់ក្នុង **ស.ក.ប.ឆ.**
- ការចំណាយលើការងារផ្សេងៗទៀតក្នុងគោលដៅធានាការប្រព្រឹត្តទៅរបស់ **ស.ក.ប.ឆ.**។

**មាត្រា៣៣ .-**

ការគ្រប់គ្រងធនធានរបស់ **ស.ក.ប.ឆ.** ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- **ស.ភ.ប.ធ.** ត្រូវបើកគណនីធនាគារណាមួយដែលស្ថិតនៅជិតទីតាំងរបស់ខ្លួន ដើម្បីធានាសុវត្ថិភាពមូលនិធិ
- **ស.ភ.ប.ធ.** ត្រូវមានបញ្ជីកាចំណូល ចំណាយត្រឹមត្រូវ
- ទ្រព្យសម្បត្តិរបស់ **ស.ភ.ប.ធ.** ត្រូវមានបញ្ជីសារពើភណ្ឌត្រឹមត្រូវ
- គណៈកម្មាធិការ **ស.ភ.ប.ធ.** ត្រូវអនុវត្តចំណូល ចំណាយដោយតម្លាភាពនិងមានឯកសារចំណូលចំណាយគ្រប់គ្រាន់
- គ្រប់កំណត់ហេតុនិងរបាយការណ៍ហិរញ្ញវត្ថុរបស់ **ស.ភ.ប.ធ.** ត្រូវបើកចំហឲ្យសមាជិករបស់ខ្លួនបានដឹងនិងអនុញ្ញាតឲ្យសមាជិកសាកសួរ ប្រសិនបើមានការសង្ស័យលើរាល់ចំណូលនិងចំណាយរបស់គណៈកម្មាធិការ **ស.ភ.ប.ធ.**
- ក្រសួងធនធានទឹកនិងឧតុនិយមមានសិទ្ធិពេញលេញក្នុងការត្រួតពិនិត្យចំណូលនិងចំណាយរបស់ **ស.ភ.ប.ធ.**។

## ជំពូកទី៨
## ការបង់ភាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ

**មាត្រា៣៤ .-**

សមាជិក **ស.ភ.ប.ធ.** មានកាតព្វកិច្ចបង់ភាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រទៅតាមលក្ខន្តិកៈ និងការព្រមព្រៀងពី **ស.ភ.ប.ធ.** ដោយមានការដឹងឮពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៣៥ .-**

គណៈកម្មាធិការ **ស.ភ.ប.ធ.** មានភារកិច្ចប្រមូលភាគទានពីអ្នកប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រទាំងអស់ ដើម្បីបម្រើឲ្យកិច្ចដំណើរការ ថែទាំ និងជួសជុលបណ្តាញធារាសាស្ត្ររបស់ខ្លួន។ នីតិវិធីនិងរូបមន្តក្នុងការគណនាភាគទានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយមនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៩
## ការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

**មាត្រា៣៦ .-**

ការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រព្រឹត្តទៅបន្ទាប់ពីប្រព័ន្ធធារាសាស្ត្រធានាបាននូវការស្រោចស្រពនិង **ស.ភ.ប.ធ.** ទទួលបាននូវការឧបត្ថម្ភគាំទ្រនិងបណ្តុះបណ្តាលពីក្រសួងធនធានទឹកនិងឧតុនិយម។

**មាត្រា៣៧ .-**

ការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រត្រូវធ្វើឡើងតាមរយៈកិច្ចព្រមព្រៀង ដោយមានការចូលរួមពី **ស.ភ.ប.ធ.** រដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ទីរធនធានទឹកនិងឧតុនិយម។

ដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋ ក្រសួងធនធានទឹកនិងឧតុនិយមអាចផ្ទេរការគ្រប់គ្រងផ្ទាល់នូវប្រព័ន្ធធារាសាស្ត្រមួយផ្នែកឬទាំងស្រុងជូន **ស.ភ.ប.ធ.**។

**មាត្រា៣៨ .-**

កិច្ចព្រមព្រៀងនៃការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ត្រូវចែងអំពីតួនាទីនិងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធរួមមាន **ស.ភ.ប.ធ.** រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរធនធានទឹកនិងឧតុនិយម និងក្រសួងធនធានទឹកនិងឧតុនិយម។ កិច្ចព្រមព្រៀងនៃការផ្ទេរនេះត្រូវចុះហត្ថលេខាដោយគ្រប់ភាគីពាក់ព័ន្ធ។

កិច្ចព្រមព្រៀងស្តីពីការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រត្រូវរៀបចំដោយក្រសួងធនធានទឹកនិងឧតុនិយម។

## ជំពូកទី១០
## ការដោះស្រាយវិវាទ

**មាត្រា៣៩ ..**

នីតិវិធីនៃការដោះស្រាយវិវាទលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក្នុងក្របខ័ណ្ឌ **ស.ក.ប.ធ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា៤០ ..**

**ស.ក.ប.ធ.** ដែលបានចុះបញ្ជីរួចហើយ ត្រូវមកបំពេញបែបបទថ្មីក្នុងរយៈពេលយ៉ាងយូរ៦ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៤១ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**

**លឹម គានហោ**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា៤២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**Kingdom of Cambodia**

**Nation Religion King**

**Royal Government of Cambodia**
**Nº...............**

# Sub-Decree
# on
# The Procedures for the Establishment, Dissolution, Roles and Duties of FWUC

## Royal Government of Cambodia

- Having seen the Constitution of the Kingdom of Cambodia;
- Having seen the Royal Decree No. NS/RKT/0913/903, dated 24 September 2013 on the Appointment of the Royal Government of Cambodia;
- Having seen the Royal Kram No. 02/NS/94 dated 20 July 1994 promulgating the Law on the Organization and Functioning of the Council of Ministers;
- Having seen the Royal Kram No. NS/RKM/0699/08 dated 23 June 1999 promulgating the Law on the Establishment of the Ministry of Water Resources and Meteorology;
- Having seen the Royal Kram No. NS/RKM/0607/016 dated 29 June 2007 promulgating the Law on the Management of Water Resources in Cambodia;
- Having seen the Sub-Decree No. 58 ORNKR.BK dated 30 June 1999 on the Organization and Establishment of the Ministry of Water Resources and Meteorology;
- Pursuant to the request of the Minister of MOWRAM.

## HEREBY DECIDE

## CHAPTER 1

## General Provisions

**Article 1.**

The objective of this Sub-Decree is to ensure the management and use of the irrigation systems in an effective and sustainable manner in the Kingdom of Cambodia.

**Article 2.**

The goal of this Sub-Decree is to define the establishment, dissolution, roles and obligations of the Farmer Water User Community in the Kingdom of Cambodia.

The acronym of Farmer Water User Community is **FWUC**.

**Article 3.**

The scope of this Sub-decree shall cover all FWUCs that use Irrigation Systems in the Kingdom of Cambodia.

**Article 4.**

The definition of key terms using in this sub-decree shall be defined as bellows:

1. **FWUC** refers to the mobilization of water users in an irrigation system area as a legal autonomous entity aimed at using that irrigation system for their agricultural production as well as for its sustainable maintenance and development, and for its modernization;

2. **Transfer of irrigation system management** refers to the delegation of responsibilities for the management and development of an irrigation system to FWUC officially established by the Ministry of Water Resources and Meteorology;

3. **Irrigation** refers to the supply and use of water from an irrigation system for agricultural production;

4. **Irrigation system** refers to a set of the water-retention, water-storing, water-delivering, and water releasing infrastructures such as main canal, first-level canal, second level canal, third level canal and quaternary canal;

5. **Maintenance of an irrigation system** refers to activities to ensure the effective and sustainable functionality of irrigation infrastructure;

6. **Repairing and rehabilitation of an irrigation system** refer to the improvement of the irrigation system infrastructure for better and more effective use;

7. **Irrigation system management plan** refers to the proposed activities and needs for the use, maintenance, improvements and small, medium and large-scale rehabilitation for short, medium and long terms;

8. **Irrigation system management** refers to leadership in the management of water use, and the maintenance, repair and improvement of irrigation infrastructure, with financing

support, implementation of regulations and adjustment;

9. **Beneficiaries-participatory irrigation system management and development** refers to participation of water users through FWUC in providing opinions for the rehabilitation, reparation or new construction of irrigation systems by government or donors;

10. **Irrigation system development** refers to the modernization of existing, and the constructions of new irrigation systems infrastructure;

11. **Irrigation-service area** refers to water irrigation on a land area under an irrigation system with clear water supply boundaries;

12. **Irrigation service plan** refers to the plan for the seasonal or annual allocation of water, indicating proposed maintenance services, the areas to be irrigated, water supply for irrigation, cropping, financing support and the irrigation service fee;

13. **Irrigation Service Fee** refers to the fee paid by all farmers using and receiving the benefit from the irrigation scheme to support the irrigation scheme;

14. **Inspection** refers to the act of inspection, evaluation and assessment of irrigation system management, the operations of the FWUC, including the budget for technical works, management and leadership;

15. **Water user** refers to farmers or individuals who use water from irrigation system for their agricultural production, fish rearing, farming or other small-scale industries;

16. **Rights to use water from irrigation system in small and medium scale** refers to the official granting of a permit by the FWUC to all institutions, individuals or water users based on the agreement between the providers and beneficiaries;

## CHAPTER 2

## Management Competency

### Article 5.

The Ministry of Water Resources and Meteorology shall have full competence on the overall management of the FWUC and shall have the roles and responsibilities, as bellow:

- Administer the FWUCs and all irrigation schemes
- Endorse the application for registration of a FWUC
- Refuse or dissolve a FWUC
- Provide guidance on the FWUC's statute and its internal regulations
- Facilitate with concerned institutions and stakeholders on the implementation and development of FWUC management
- Coordinate and facilitate the elections of the FWUC Committees
- Settle disputes within the FWUC context
- Seek other funding sources to support the FWUCs
- Provide training to enhance the capacity of FWUCs

### Article 6.

The Provincial Department/Municipality of Water Resources and Meteorology shall register all FWUCs in the FWUC registry, after endorsement by MOWRAM.

## Chapter 3

## Establishment and Dissolution of FWUCs

**Article 7.**

A FWUC is an entity serving a common interest of people through the use of an irrigation system in an effective and sustainable manner aimed at enhancing economic and, social development, and poverty reduction.

A FWUC shall be established based on the following criteria:

- The farmers that use water within the same irrigation scheme or part thereof;
- Compliance with the technical standard of MOWRAM;
- Participation in the election of those who use the irrigation system under the FWUC competence, with the support of two third of voters. Those who use the irrigation system under the jurisdiction of the FWUC may apply for FWUC membership, although they do not participate in the elections;
- The Laws, regulations, and concerned legal documents.

**Article 8.**

The dissolution of a FWUC shall be determined by a Prakas of the Minister of MOWRAM.

## Chapter IV
## Membership, Roles, Duties and Rights of the FWUCs

**Article 9.**

A citizen who wishes to be member of a FWUC must meet the following conditions:

- Be a landowner or tenant whose land is located in the irrigation system;
- Be at least eighteen years old of either sex; in a case where the landowner is under eighteen, his/her legal guardian shall represent him/her, unless otherwise agreed;
- Submission of his/her application for FWUC membership with his/her thumb print

**Article 10.**

FWUC membership shall be terminated in the following conditions:

- S/he has passed away;
- His/her landownership is hired to another, or sold or transferred to another;

- His/her contract for hired land fininished
- S/he breaks the law, or fails to comply with the regulations, concerned legal documents, the FWUC statute and its internal regulations, or his/her membership is withdrawn by the FWUC committee.

**Article 11.**

The roles and obligations of a FWUC are as follows:

- Participate in managing the irrigation system in conformity with legal frameworks in relation to the irrigation sector;
- Comply with the guidelines of MOWRAM;
- Implement the laws, regulations, concerned legal frameworks, statutes and internal regulations of the FWUC;
- Develop a plan, and ensure its appropriate implementation, for the repair, improvement, and increased productivity of the irrigation system;
- Participate in inspections of the irrigation system as scheduled and in accordance with the regulations, orders, concerned legal frameworks and policies of the Royal Government;
- Provide information to, or consult with sub-national authorities, or participate in the decision-making on related action plans or local development activities;
- Protect the land areas locate within the reservoir of an irrigation scheme and its surrounding from any encroachment;
- Encourage the FWUC members to pay the Irrigation Service Fee;
- Resolve any disputes resulting from water use and its distribution for different purposes;
- Prepare six-monthly and annual reports and submit them to MOWRAM.

**Article 12.**

A FWUC shall have the following rights:

- Approve or amend its statute and its internal regulations;
- Elect and change the FWUC Committee composition pursuant to the FWUC statute;
- Get advantages from the natural resources within the whole limit of the irrigation schemes including other businesses, such as farming, fish ponds and tourism;
- Use, distribute water within, manage and maintain the irrigation system;
- Open a bank account and use its budget based on the FWUC statute;
- Sign contracts for the supply and receipt of other services, selection of and change a service provider with other parties that provide benefits to the FWUC;
- Request financial and technical assistance or other support from the Royal Government or other parties;
- Request and select supporting services for capacity building for the FWUC requirement from funding institutions, non-governmental organizations, development organizations, the private sector and other contributors,

**Article 13.**

The FWUC shall not:

- Sell and privately share the irrigation system infrastructures in any form;
- Be a party to any agreement with any individual or entityto modify or construct any new irrigation scheme infrastructure without permission from MOWRAM.

**Article 14.**

A FWUC member shall have the following roles and obligations:

- Comply with and implement the laws, regulations, related legal documents, statute, internal regulations and irrigation service plan of the FWUC;
- Participate in protecting fisheries, wildlife and forests within the reservoir area and its surrounding lands, or within the irrigation system area;
- Assist the FWUC Committee in protecting the irrigation system to ensure sustainable operations;
- Use water in accordance with the volume set by the FWUC Committee;
- Regularly monitor the water provided from the point where it is received in their cultivated areas or farms, and ensure effective use;
- Pay the irrigation service fee and contribute human labor or material that the FWUC may require to ensure sustainable O&M and other development purpose of the FWUC;
- Inform the FWUC Committee and the local authorities of any activities or encroachments which may cause damage to the irrigation system infrastructures and stop such illegal activities.

**Article 15.**

A FWUC member shall have the following rights:

- Participate in approving the FWUC statute and its internal regulations;
- Share his/her opinion at meetings to improve working modality;
- Participate in the election of new members of the FWUC or in a FWUC member change;
- Be a candidate for the FWUC Committee structure;
- Vote for or against activities and the work plan of the FWUC;
- Receive water distributed for his/her use for agricultural production, and other services in accordance with the irrigation plan;
- Receive equitable and justifiable conflict resolution;
- Request for clarification on financial reports and other reports of the FWUC, if they are not clear;
- Resign from the FWUC.

## Chapter V
## The FWUC Committee

**Article 16.**

The FWUC shall be led by a FWUC Committee, in short FWUC, to be elected by the voting of the FWUC members. The FWUC shall be divided into farmer water user groups, in short FWUGs.

In case where the irrigation system is large and complex, a FWUC may establish one or more Farmer Water User sub-Groups, in short FWUSG.

The FWUC Committee shall have the following composition:

| | |
|---|---|
| - Chairperson (01) | overall leadership and accountability |
| - 1st Vice-Chairperson (01) | responsible for O&M |
| - 2nd Vice-Chairperson (01) | responsible for water sharing |
| - Accountant (01) | responsible for all financial matters |
| - The Chairpersons of the FWUGs | |

For a large irrigation system, the chairperson of the FWUC may submit a request to MOWRAM for a co-Chairpersonship to suit the local real situation.

The FWUG and FWUSG shall have the following composition:

- Chairperson (01)
- Assistants as needed

The Chairperson of the FWUG and the FWUSG shall be elected by their respective members.

**Article 17.**

The term of the FWUC Committee shall be for five years and may be extended until a new elected FWUC Committee assumes it functions.

In cases when a member of the FWUC Committee passes away or resigns or is expelled from FWUC prior to three months before the end of the FWUC term, the FWUC shall elect a new member for his/her replacement.

Any former FWUC Committee member shall have the right to be a candidate for the election of a new FWUC.

In cases when the Chairperson of the FWUG or FWUSG is elected as the Chairperson, Vice-Chairperson, or Accountant of the FWUC, the related FWUG or FWUSG shall select a new Chair as a replacement.

**Article 18.**

The election of the FWUC Committee shall be conducted at the same time in 4 stages through four separate elections. The first election shall be for the Chairperson, the second for the First Vice-Chairperson, the third for the Second Vice-Chairperson and the forth for the accountant.

A valid election requires the presence at least two third (2/3) of the total FWUC membership.

The election of the FWUC Committee members shall be based on a majority of the votes. In cases where the votes for a member are equal, the eldest candidate shall be selected.

The results of the election shall be approved by a Prakas and announced by the Minister of MOWRAM.

**Article 19.**

The FWUC Committee shall have the following roles and obligations:

- Prepare the work plan for the FWUC;

- Prepare the FWUC Statute, contracts, internal regulations, agreement on the transfer of the irrigation system, and the irrigation service plan;
- Maintain the irrigation system in good condition to enable the irrigation water supply;
- Manage and allocate the water fairly to all members of the community;
- Build up capacity in the field of water use, maintenance, and development of the irrigation system;
- Prepare reports on FWUC works and send them to MOWRAM for consideration and assessment;
- Resolve any conflicts arising within the community;
- Collect contribution within the irrigation system, including other revenue from other exploitation activities within the FWUC irrigation system for the purpose of sustainable O&M of the irrigation system;
- Impose any administrative punishment on any FWUC member, any member of the FWUC Committee, and the Chairperson of the FWUC basing on the FWUC Statute.

**Article 20.**

The Chairperson of the FWUC Committee shall have the following roles and obligations:

- Invite the FWUC Committee members to a meeting;
- Chair the meetings dealing with irrigation works;
- Lead the preparation of the yearly work plan and the required budget for the expenditures;
- Ensure the implementation of all activities in accordance with the work plan and other activities agreed upon at the meeting of the FWUC Committee;
- Monitor all activities of the FWUG;
- Cooperate on all public works;
- Ensure that all expenditure is undertaken in conformity with the decisions of the FWUC Committee;
- Ensure that the agenda of the FWUC Committee’s meeting includes the draft program of activity and the associated annual budget for expenditure;
- Approve the revenue and other expenditures within the context of the FWUC Committee;
- Resolve conflicts arising among FWUC members.

In cases where the Chairperson cannot be present at a meeting or is absent for an extended period, s/he shall give full power to the First or Second Vice-Chairperson to lead the Committee’s work. In cases when both of Vice-Chairpersons are absent, the Chairperson shall nominate any member of the Committee to lead the Committee’s work.

**Article 21.**

The First Vice-Chairperson shall have the following roles and obligations:

- Continuously monitor the irrigation system;
- Propose works to the FWUC Committee members for O&M;
- Stop all activities which may damage or destroy the dams and canals;
- Prepare plans for the repair of the irrigation system for their submission to the FWUC Committee for consideration and approval;
- Periodically prepare reports on the repair of the irrigation system and submit them to the Chairperson of the FWUC Committee;

- Assist the FWUC Committee Chairperson's works.

**Article 22.**

The Second Vice-Chairperson shall have the following roles and obligations:

- Prepare plans for irrigated cropping with the agreement of all members;
- Set tasks and responsibilities to the head of FWUGs in implementing the irrigation program;
- Monitor the implementation of the irrigation program and report to the Chairperson of the FWUC Committee on irrigation activities;
- Assist the FWUC Committee Chairperson's works.

**Article 23.**

The Accountant shall have the following roles and obligations:

- Collect contribution from members through the chairperson of the FWUGs;
- Prepare the inventory of mobile and immobile assets of the FWUC Committee;
- Manage all revenues and expenditures of the FWUC Committee;
- Prepare financial reports on the FWUC for the FWUC Committee;
- Make all payments or money transfers within the context of the FWUC Committee.

**Article 24.**

The Head of the FWUG shall have the following roles and obligations:

- Implement the FWUC activities according to the approved work program;
- Arrange all activities between its members and the FWUC Committee;
- Collect the contribution from FWUG members in accordance with FWUC Statute;

The Head of a FWUSG shall have the same roles and obligations as the Head of a FWUG.

## Chapter 6

## Procedures for the Registration of FWUC

**Article 25**

The FWUC Statute should include the following:

- Name of the FWUC;
- Objectives of the FWUC;
- Criteria for the membership of the FWUC;
- Structure of the FWUC;
- Name and address of the members of the FWUC Committee who have his/her land in the irrigation system area;
- Mandate and functions of the FWUC;
- Revenue, expenditures and monitoring processes of the FWUC.

**Article 26.**

The FWUC Statute shall be approved by its members. The FWUC Committee shall apply to register its Statute at the Provincial Department of Water Resources and Meteorology, herein PDWRAM, of the province where FWUC is located.

**Article 27.**

The PDWRAM, prior to registering of the FWUC Statute, shall send all related documents within twenty working days, from the date when the FWUC State was received for registration, to MOWRAM for endorsement.

**Article 28.**

MOWRAM shall check and endorse the request of the PDWRAM for FWUC Statute registration within twenty working days from the date when the application was received.

In cases where the MOWRAM finds that the received application is not in conformity with the set procedures, the concerned PDWRAM shall follow MOWRAM's advice.

In cases where PDWRAM cannot follow the instructions of MOWRAM, MOWRAM may refuse such application for registration.

In cases where there is no confirmation on the request for registration of the FWUC Statute from MOWRAM within the period of time as mentioned in Paragraph one of this Article, the registration shall be automatically registered the concerned PDWRAM.

**Article 29.**

Once MOWRAM endorses the request for the registration of the FWUC Statute, the PDWRAM shall register the Statute in its FWUC Statute list and officially inform the FWUC that it has full rights to implement its Statute.

**Article 30.**

A registered FWUC that wishes to amend its Statute shall reapply for registration of its amended Statute by maintaining the same ordinal number in the registration list.

## Chapter 7

## Financial Sources and Management

**Article 31.**

Financial sources of a FWUC may include:

- The contribution from the use of irrigation service collected from the mebers;
- Other contribution collected from other exploiters and services within the reservoir or the Irrigation scheme;
- Contributions from FWUC members such as in human labors and other contribution as set by the FWUC;
- Financial support or donations from donors and other generous persons;
- Revenues from any business activities undertaken by the FWUC;
- Other administrative fines;

- National budget;
- Other legal revenue sources.

**Article 32.**

The use of financial sources shall be for the following:

- Regular operation and maintenance of the irrigation system;
- Regular repairs, small-scale rehabilitation and improvements;
- Contributions to the repair, large-scale rehabilitation and improvements to the capacity of the irrigation system that are funded by the Government, donors or other contributors;
- Allowance for the FWUC committee, administrative works and material use within the FWUC;
- Expenditure on the other works to ensure FWUC operations.

**Article 33.**

The financial management of FWUC shall follow the below principles:

- The FWUC shall open an account in a bank located near its office to ensure security of all funds;
- Assets and fixed assets used in FWUC activities shall be appropriately recorded in the inventory;
- Income or materials received from FWUC members, entities, institutions, organizations or other donors shall be properly receipted;
- The FWUC Committee shall file all receipts and records relating to revenues and expenditures;
- Financial records and reports of the FWUC shall be open to all FWUC members for their understanding, and they may question the records.
- MOWRAM has the authority to inspect the revenues and expenditures of the FWUC.

## Chapter 8

## Irrigation Services Contribution

**Article 34.**

The FWUC members have the obligation to pay the irrigation services contribution in accordance with the Statute and the agreement and approval of the FWUC, supported by sub-national level authorities.

**Article 35.**

The FWUC Committee shall be responsible for collecting irrigation service contribution from all customers. The Procedures and formula for calculation of irrigation service contribution shall be defined by a inter-ministerial Prakas of the Minister of MOWRAM and Minister of MEF.

## Chapter 9

## Irrigation System Management Transfer

**Article 36.**

The transfer of irrigation system management shall be only made after the irrigation scheme where its irrigation has been ensured and the concerned FWUC has been supported and trained by MOWRAM.

**Article 37.**

The transfer of the management of an irrigation system shall be made through an agreement with the participation of the FWUC, sub-national level authorities, and PDWRAM.

MOWRAM may partly or fully transfer the management of an irrigation system to be directly under the management of the FWUC to reduce the government's expenditures.

**Article 38.**

The agreement on the transfer of an irrigation system management shall define the roles and responsibilities of related stakeholders, such as the FWUC, sub-national level authorities, the PDWRAMs, and MOWRAM. This agreement shall be signed by all related parties.

The agreement on the transfer of an irrigation system management shall be prepared by MOWRAM/

## Chapter 10

## Conflict Resolution

**Article 39.**

The procedures on conflict resolution within the context of FWUCs shall be defined by a Prakas of MOWRAM.

## Chapter 11
## Intermediate Provision

**Article 40.**

The registered FWUC shall resubmit its application within a period of six(06) months after this sub-decree is in force.

## Chapter 12
## Final Provisions

**Article 41.**

Any provision whose content is contrary to that of this Sub-decree shall be considered void and null.

**Article 42.**

The Minister in charge of the Office of the Council of Ministers, the Minister of Water Resources and Meteorology, the Minister of Economy and Finance, the Ministers and the Secretaries of State of all concerned Ministries shall effectively implement this sub-decree from the signed date on ward.

Phnom Penh, 12 March2015

**Prime Minister**

**SamdechAkkaMohaSenaPadeiTecho HUN SEN**

For its respectful submission to Samdech
Akka Moha Sena Padei Techo Prime Minister
For his signature
Minister of MOWRAM

KLim Kean Hor

**CC:**

- Ministry of Royal Palace
- General Secretariat of Constitutional Council
- General Secretariat of Senate
- General Secretariat of National Assembly
- General Secretariat of the Royal Government of Cambodia
- Cabinet of Prime Minister
- Cabinets of the Deputy Prime Ministers
- Cabinets of the Municipality/provinces
- As mentioned in Article 42
- Archives-chronicles
- Royal affairs